ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ការិយាល័យសន្តិសុខថ្នាក់កណ្តាល
លេខៈ...៥១..........ស.ស.រ

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតក្រុមប្រចាំការអចិន្ត្រៃយ៍របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល

## ការិយាល័យសន្តិសុខថ្នាក់កណ្តាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញអនុក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
-បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
-បានឃើញសេចក្តីសំរេចលេខ ៥៥សសរ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតគណៈបញ្ជាការការពារការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣
-ផ្អែកតាមការចាំបាច់របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល

## សំរេច

**ប្រការ១** : ត្រូវបានបង្កើតក្រុមប្រចាំការអចិន្ត្រៃយ៍របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ដែលមានសមាសភាពដូចខាងក្រោម :

| | | | |
|---|---|---|---|
| ១-ឧ.ឧ. ឧត្តមសេនីយ៍ឯក | នេត សាវឿន | អគ្គស្នងការរងនគរបាលជាតិ | ជាប្រធាន |
| ២-ឧ.ឧ. ឧត្តមសេនីយ៍ឯក | ជា តារា | នាយករងសេនាធិការចំរុះ និងជានាយកទីចាត់ការកលយុទ្ធ | ជាអនុប្រធាន |

| | | | |
|---|---|---|---|
| ៣-ឯ. ឧ. ឧត្តមសេនីយ៍ទោ | **សុខ ផល** | ប្រធាននាយកដ្ឋានព័ត៌មានទូទៅ | ជាសមាជិក |
| ៤-ឯ. ឧ. ឧត្តមសេនីយ៍ទោ | **ខៀវ សុគ៌ត** | អគ្គលេខាធិការរង ក្រសួងមហាផ្ទៃ | ជាសមាជិក |
| ៥-ឯ. ឧ. ឧត្តមសេនីយ៍ទោ | **ម៉ៅ ចំនួនតារា** | ប្រធានលេខាធិការ | ជាសមាជិក |
| ៦-ឯ. ឧ. ឧត្តមសេនីយ៍ទោ | **ខន្ធ ពិសេន** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស | ជាសមាជិក |

<u>**ប្រការ២**</u> : ក្រុមប្រចាំការអចិន្ត្រៃយ៍មានភារកិច្ច :

-ជួយការិយាល័យសន្តិសុខថ្នាក់កណ្តាល តាមដាន ត្រួតពិនិត្យការអនុវត្តផែនការលេខ ០១៨.ក ចុះថ្ងៃទី១៣/០១/២០០៣ ស្តីពីវិធានការការពារសុវត្ថិភាពក្នុងដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី៣ របស់ការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-តាមដាន ប្រមូលផ្តុំព័ត៌មាន សភាពការណ៍សន្តិសុខ សណ្តាប់ធ្នាប់ជុំវិញការឃោសនាបោះឆ្នោត និងការបោះឆ្នោត ពីបណ្តាអង្គភាពជំនាញ និងពី គ្រប់ខេត្ត-ក្រុង រាយការណ៍ជូនការិយាល័យសន្តិសុខថ្នាក់កណ្តាល ។

-បញ្ជាដឹកនាំដោះស្រាយរាល់សភាពការណ៍ ពេលមានករណីចាំបាច់ ឬ ឧប្បត្តិហេតុផ្សេងៗទាក់ទងដល់សន្តិសុខការបោះឆ្នោត ដោយសហការជាមួយការិយាល័យ សន្តិសុខថ្នាក់ខេត្ត-ក្រុង និងសមត្ថកិច្ចពាក់ព័ន្ធ ។

<u>**ប្រការ៣**</u> : ក្រុមប្រចាំការអចិន្ត្រៃយ៍មានសិទ្ធិប្រើប្រាស់ ដឹកនាំកម្លាំង និងមធ្យោបាយក្រោមឱវាទរបស់ខ្លួន ដើម្បីជាជំនួយការក្នុងកិច្ចចាំបាច់ ដើម្បីសំរេចភារកិច្ចដូចមានចែងក្នុង ប្រការ២ ។

<u>**ប្រការ៤**</u> : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងសាមីខ្លួនដែលមានឈ្មោះក្នុង ប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០០៣
**ឧបនាយករដ្ឋមន្ត្រី**
**ទីប្រឹក្សាប្រធានការិយាល័យសន្តិសុខថ្នាក់កណ្តាល**

<u>**ចំលងជូន:**</u>
*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត*
*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី ស ខេង*
*-ក្រសួងមហាផ្ទៃ*
*-ក្រសួងការពារជាតិ*
*-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
*-អគ្គមេបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ*
*-អគ្គស្នងការដ្ឋាននគរបាលជាតិ*
*-បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស*
*-គ្រប់សាលាខេត្ត-ក្រុង*
*-ដូច ប្រការ១*
*-ឯកសារ-កាលប្បវត្តិ*

HQ1-Decision27-06-03